# របាយការណ៍

## ឯកឧត្តម សួស ប្រាថ្នា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល

## ស្តីពីសមិទ្ធផលការងារសម្រេចបានសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២-២០២៥

ថ្ងៃទី៧-៨ ខែកញ្ញា ឆ្នាំ២០២៦ ម៉ោង០៨:០០នាទីព្រឹក

សណ្ឋាគារសុខាវ៉េស៊ីដង់ ភ្នំពេញ

ជាបឋម...

- ខ្ញុំបាទសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ចំពោះ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រី ទទួលបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.អ.ប
- សូមគោរព ឯកឧត្តម សន្តិបណ្ឌិត ម៉ៅ ចន្ទតារា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ
- ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន
- ឯកឧត្តម ប្រធានក្រុមប្រឹក្សា/ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិ-រាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ ដែលបានអញ្ជើញចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ ជាទីគោរពនិងជាទីមេត្រី!

ក្នុងនាមអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងក្នុងនាមសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តម របស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីក្នុងពិធី«**សន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥**» នាពេលនេះ។ វត្តមានរបស់ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

**ក្រសួងមហាផ្ទៃ** គឺបានបញ្ជាក់អំពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការនិងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្មសម្រេចបានសមិទ្ធផលជាច្រើនជូនសង្គមជាតិនិងប្រជាពលរដ្ឋ។ ស្ថិតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទមានកិត្តិយសសូមគោរពធ្វើសេចក្តីរាយការណ៍ដោយសង្ខេបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** គណៈអធិបតី និងអង្គសន្និបាតទាំងមូល មេត្តាជ្រាបអំពីសមិទ្ធផលការងារសំខាន់ៗបញ្ជាប្រយម ក្នុងអាណត្តិទី៥ និងទិសដៅការងារសម្រាប់អនុវត្តអាណត្តិទី៦របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម៖

## I-សាវតារនៃកំណែទម្រង់និងបរិបទអាណត្តិទី៥៖

*១-សាវតារនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ៖* ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាសសរស្តម្ភដ៏មានសារៈសំខាន់នៃកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ បង្កើនភាពជាម្ចាស់ ការចូលរួម ព្រមទាំងធានាឱ្យការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបបានចំទិសដៅ និងទាន់ពេលវេលាចំពោះតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ដំណើរការកំណែទម្រង់ជាប្រវត្តិសាស្ត្រនេះ ត្រូវបានចាប់ផ្តើមជាផ្លូវការនៅថ្នាក់មូលដ្ឋាន តាមរយៈការប្រកាសឱ្យប្រើប្រាស់ «ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់» និង «ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់» ក្នុងឆ្នាំ២០០១។ ផ្អែកលើមូលដ្ឋានគតិយុត្តទាំងពីរនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាលើកដំបូងត្រូវបានរៀបចំឡើងដោយជោគជ័យនៅឆ្នាំ២០០២ ដែលជាព្រឹត្តិការណ៍បើកទំព័រថ្មីក្នុងការផ្លាស់ប្តូររដ្ឋបាលឃុំ សង្កាត់ ពីយន្តការដឹកនាំតាមការចាត់តាំងទៅជារដ្ឋបាលមូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោតផ្ទាល់ពីប្រជាពលរដ្ឋ មានភាពជាតំណាងស្របច្បាប់ និងមានគណនេយ្យភាពចំពោះម្ចាស់ឆ្នោត។

ដោយមើលឃើញពីសមិទ្ធផលជាផ្លែផ្កានៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានបន្តពង្រីកវិសាលភាពកំណែទម្រង់នេះទៅកាន់ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការដាក់ឱ្យអនុវត្ត «ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ» ក្នុងឆ្នាំ២០០៨ ដោយឈរលើគោលការណ៍ដឹកនាំតាមបែប «រដ្ឋបាលឯកភាព» ដើម្បីធានាការសម្របសម្រួល និងការទទួលខុសត្រូវច្បាស់លាស់រវាងរដ្ឋបាលថ្នាក់នីមួយៗ។ ទន្ទឹមនេះ ដើម្បីកំណត់ទិសដៅយុទ្ធសាស្ត្រវែងឆ្ងាយ រាជរដ្ឋាភិបាលបានដាក់ចេញ «កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១០-២០២០)» ដោយផ្តោតលើការរៀបចំស្ថាប័នការផ្ទេរមុខងារ និងធនធាន ព្រមទាំងការកសាងសមត្ថភាពធនធានមនុស្ស។ បន្ទាប់ពីបញ្ចប់

ដំណាក់កាលទី១ ប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលបានបន្តដាក់ឱ្យអនុវត្ត «កម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០)» សំដៅធ្វើឱ្យកំណែទម្រង់កាន់តែស៊ីជម្រៅ តាមរយៈការពង្រឹងស្ថាប័ន និងការបែងចែកមុខងារ ធនធាន សិទ្ធិសម្រេច និងខ្សែគណនេយ្យភាពឱ្យកាន់តែច្បាស់លាស់រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

*២-ការវិវត្តតាមអាណត្តិនៃក្រុមប្រឹក្សាឃុំ សង្កាត់* (២០០២-២០២៥)៖ ក្នុងដំណើរការជាងពីរទសវត្សរ៍កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជា បានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមអាណត្តិ៥ឆ្នាំម្តង បានចំនួន៥លើករួចមកហើយ រួមមាន៖

- អាណត្តិទី១ (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០២)៖ ដែលមានសមាជិកក្រុមប្រឹក្សាសរុបចំនួន **១១.២៦១រូប**។
- អាណត្តិទី២ (ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧)៖ ដែលមានសមាជិកក្រុមប្រឹក្សាសរុបចំនួន **១១.៣៥៣រូប**។
- អាណត្តិទី៣(ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២)៖ មានសមាជិកក្រុមប្រឹក្សាសរុបចំនួន **១១.៤៥៩រូប**។
- អាណត្តិទី៤ (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧)៖ មានសមាជិកក្រុមប្រឹក្សាសរុបចំនួន **១១.៥៧២រូប**។
- អាណត្តិទី៥ (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២)៖ មានសមាជិកក្រុមប្រឹក្សាសរុបចំនួន **១១.៦២២រូប**។

ការរៀបចំការបោះឆ្នោតជាទៀងទាត់នេះ បានពង្រឹងនូវនិរន្តរភាព ភាពស្របច្បាប់ និងភាពជាតំណាងរបស់រដ្ឋបាលមូលដ្ឋាន ព្រមទាំងផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តសិទ្ធិអំណាចនិងស្វ័យភាពក្នុងការដឹកនាំ គ្រប់គ្រង ការចាត់ចែងថវិកា និងការកសាងសមិទ្ធផលជូនសង្គមជាតិកាន់តែរឹងមាំ។ ជាសក្ខីភាព ធនធានមូលនិធិឃុំ សង្កាត់ ដែលជាប្រភពហិរញ្ញវត្ថុស្នូល បានកើនឡើងជាលំដាប់ពីប្រមាណជិត **៨លាន**ដុល្លារអាម៉េរិក(នៅក្នុងឆ្នាំ២០០២) រហូតដល់ប្រមាណ **៣៣៣លាន**ដុល្លារអាម៉េរិក(ក្នុងឆ្នាំ២០២៦ ដោយរួមបញ្ចូលទាំងធនធានបន្ថែម និងចំណូលពន្ធចែករំលែក)។

*៣-បរិបទអាណត្តិទី៥ និងសារៈសំខាន់នៃការរៀបចំសន្និបាត៖* ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥(២០២២-២០២៥) បានបំពេញបេសកកម្មក្នុងបរិបទយុទ្ធសាស្ត្រដ៏សំខាន់ ដែលស្របពេលគ្នានឹងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ និងការដាក់ចេញនូវយុទ្ធសាស្ត្របញ្ច-

កោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ នេះជាដំណាក់កាលនៃការផ្លាស់ប្តូរជាយុទ្ធសាស្ត្រ ពីការផ្តោតជាចម្បងលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទៅរកការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ដែលរួមបញ្ចូលនូវការលើកកម្ពស់សេវាសង្គម ការគាំពារសង្គម ការអប់រំកុមារតូច កិច្ចការពារស្ត្រីនិងកុមារ អនាម័យបរិស្ថាន ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការធ្វើបរិវត្តកម្មឌីជីថល។

ការរៀបចំ «សន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥» នាពេលនេះ គឺជាសន្និបាតលើកទី៣ (បន្ទាប់ពីការរៀបចំនៅអាណត្តិទី១ និងទី២) ដែលមានតម្លៃជាប្រវត្តិសាស្ត្រក្នុងការៈ ១.ឆ្លុះបញ្ចាំង និងវាយតម្លៃលើដំណើរការអនុវត្តតួនាទី ភារកិច្ច និងសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រយៈពេលជាង៤ឆ្នាំកន្លងមក(២០២២-២០២៥) ក៏ដូចជាពិនិត្យមើលលើវឌ្ឍនភាពរយៈពេលជាងពីរទសវត្សរ៍នៃកំណែទម្រង់រដ្ឋបាលមូលដ្ឋាន, ២.កំណត់ឱ្យបានច្បាស់លាស់នូវផលជះនៃការអនុវត្តគោលនយោបាយ ស្ថានភាពនិងសមត្ថភាពធនធានមនុស្ស ព្រមទាំងបញ្ហាប្រឈមនិងហានិភ័យគន្លឹះនានា ៣.ដកស្រង់ឧត្តមានុវត្តន៍ និងមេរៀនបទពិសោធដើម្បីបម្លែងជាធាតុចូលយុទ្ធសាស្ត្រ ក្នុងការកំណត់ទិសដៅ វិធានការ និងអនុសាសន៍គន្លឹះៗសំដៅគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ឱ្យបំពេញតួនាទីកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងឆ្លើយតបបានកាន់តែល្អប្រសើរចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## II-សមាសភាព រចនាសម្ព័ន្ធ និងធនធានមនុស្សៈ

ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាស្ថាប័នតំណាងប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន ដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ សកល សេរី ត្រឹមត្រូវ និងសម្ងាត់។ ក្រុមប្រឹក្សាមានតួនាទីដឹកនាំគ្រប់គ្រង ធ្វើសេចក្តីសម្រេចចិត្តនិងត្រួតពិនិត្យការអនុវត្តកិច្ចការរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌។ ដើម្បីធានាឱ្យដំណើរការដឹកនាំ និងការចាត់ចែងការងារប្រព្រឹត្តទៅដោយរលូន ទាំងរចនាសម្ព័ន្ធ និងធនធានមនុស្សរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

***១-សមាសភាព និងភាពជាតំណាងៈ*** ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ គ្របដណ្តប់លើរដ្ឋបាលឃុំ សង្កាត់ចំនួន **១.៦៥២** នៅទូទាំងប្រទេស។ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានចំនួនសមាជិកក្រុមប្រឹក្សាចាប់ពី ៥រូប ដល់ ១១រូប អាស្រ័យលើកត្តាប្រជាសាស្ត្រ និងទំហំភូមិសាស្ត្រជាក់ស្តែង។ ទូទាំងប្រទេស

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកសរុបចំនួន **១១.៦២២រូប** ក្នុងនោះស្ត្រីមានចំនួន **២.៥៦៩រូប** (ស្មើនឹង **២២,៣%** នៃសមាជិកសរុប) ដោយមានការបែងចែកតាមមុខតំណែងដឹកនាំដូចខាងក្រោម៖

- មេឃុំ៖ សរុបចំនួន **១.៣៨៥រូប** (ស្ត្រីចំនួន **១៣៩រូប**)
- ចៅសង្កាត់៖ សរុបចំនួន **២៦៧រូប** (ស្ត្រីចំនួន **៣៤រូប**)
- ជំទប់ទី១៖ សរុបចំនួន **១.៣៨៥រូប** (ស្ត្រីចំនួន **២៧៣រូប**)
- ជំទប់ទី២៖ សរុបចំនួន **១.៣៨៥រូប** (ស្ត្រីចំនួន **១៦០រូប**)
- ចៅសង្កាត់រងទី១៖ សរុបចំនួន **២៦៧រូប** (ស្ត្រីចំនួន **៦៧រូប**)
- ចៅសង្កាត់រងទី២៖ សរុបចំនួន **២៦៧រូប** (ស្ត្រីចំនួន **៣៩រូប**)
- សមាជិកក្រុមប្រឹក្សាផ្សេងទៀត៖ សរុបចំនួន **៦.៦៦៦រូប**(ស្ត្រីចំនួន**១.៨៥៧រូប**)។

ទិន្នន័យខាងលើនេះ បានបង្ហាញពីភាពជាតំណាងស្របច្បាប់ និងទូលំទូលាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស។ ទន្ទឹមនឹងការកើនឡើងនៃវត្តមាន និងតួនាទីរបស់ស្ត្រីក្នុងជួរថ្នាក់ដឹកនាំនៅមូលដ្ឋាន ភាគរយនៃស្ត្រីជាមេឃុំនិងចៅសង្កាត់នៅតែមានកម្រិតទាបនៅឡើយ បើប្រៀបធៀបនឹងបុរស ដែលចំណុចនេះត្រូវបន្តយកចិត្តទុកដាក់លើកកម្ពស់បន្ថែមទៀតក្នុងអាណត្តិខាងមុខ។

*២-ស្មៀនឃុំ សង្កាត់ និងបុគ្គលិកគាំទ្រ៖* ដើម្បីគាំទ្រដល់ដំណើរការការងាររបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានា យន្តការសេនាធិការរដ្ឋបាល និងបុគ្គលិកជំនួយការរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ក្នុងនោះ៖

- **ស្មៀនឃុំ សង្កាត់៖** ស្មៀនគឺជាសេនាធិការស្នូលឲក្រុមប្រឹក្សាក្នុងការរៀបចំកិច្ចប្រជុំ ការតាក់តែងដីកា សេចក្តីសម្រេច គ្រប់គ្រងឯកសារ លិខិតបទដ្ឋាន គាំទ្រការរៀបចំផែនការ ថវិកា និងសម្របសម្រួលការផ្តល់សេវារដ្ឋបាលប្រចាំថ្ងៃជូនប្រជាពលរដ្ឋ។ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានស្មៀនចំនួន១រូប ដែលជាមន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ។ ក្នុងអាណត្តិទី៥នេះ មានស្មៀនសរុបចំនួន **១.៦៥២**រូប (ស្ត្រីចំនួន **៣២៦រូប** ស្មើនឹងប្រមាណ **២០%**)។
- **បុគ្គលិកកិច្ចសន្យា៖** ដើម្បីឆ្លើយតបទៅនឹងទំហំការងារ និងមុខងារដែលត្រូវបានផ្ទេរបន្ថែម ក្រុមប្រឹក្សាឃុំ សង្កាត់បានជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាសរុបប្រមាណ **៨.០៤៥នាក់**ទូទាំងប្រទេស រួមមាន៖

- ✓ **ជំនួយការរដ្ឋបាល៖** មានចំនួន **២.៨៦៣នាក់** (ស្ត្រី **១.៣៩២នាក់**) ទទួលបន្ទុកការងារលិខិតស្នាម បណ្ណសារ ការផ្ដល់សេវា និងការបញ្ចូលទិន្នន័យ។
- ✓ **ជំនួយការហិរញ្ញវត្ថុ៖** មានចំនួន **១.៦៥២នាក់** (ស្ត្រី **៣២៦នាក់**) ទទួលបន្ទុកការងារគណនេយ្យ ថវិកា លិខិតយុត្តាធិការ និងរបាយការណ៍ហិរញ្ញវត្ថុ។
- ✓ គ្រូមត្តេយ្យសិក្សាសហគមន៍៖ មានចំនួន **៣.៣៤៨នាក់** (ស្ត្រី **២.៨៩៦នាក់**) បំពេញភារកិច្ចបង្រៀន និងថែទាំកុមារតូចនៅតាមសហគមន៍។
- ✓ ជំនួយការសេវាសង្គម និងអនាម័យបរិស្ថាន៖ មានចំនួន **១៨២នាក់** (ស្ត្រី **១៣៦នាក់**) ជួយសម្របសម្រួលសកម្មភាពគាំពារសង្គម ជនងាយរងគ្រោះ និងការគ្រប់គ្រងបរិស្ថានមូលដ្ឋាន។

ការបង្កើតមុខតំណែងជំនួយការទាំងនេះ បានឆ្លុះបញ្ចាំងពីការប្រែក្លាយរដ្ឋបាលឃុំ សង្កាត់ពីស្ថាប័នរដ្ឋបាលសាមញ្ញ ទៅជារដ្ឋបាលមូលដ្ឋានដែលទាមទារនូវជំនាញបច្ចេកទេសចម្រុះ និងមានរចនាសម្ព័ន្ធការងារកាន់តែរឹងមាំនិងទូលំទូលាយ។

***៣-ការគ្រប់គ្រងភូមិ និងរចនាសម្ព័ន្ធមន្ត្រីភូមិ៖*** ភូមិគឺជាយន្តការរដ្ឋបាលដែលស្ថិតនៅកៀកជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ និងជាស្ពានតភ្ជាប់មិនអាចខ្វះបានរវាងសហគមន៍មូលដ្ឋានជាមួយរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ និងរាជរដ្ឋាភិបាល ក្នុងនោះ៖

- **រចនាសម្ព័ន្ធភូមិ៖** បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានភូមិសរុបចំនួន **១៤.៥៩០** ភូមិ ដែលភូមិនីមួយៗត្រូវបានកំណត់លេខកូដសម្គាល់ស្តង់ដាជាផ្លូវការ ស្របតាមអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីធានាសង្គតិភាពនៃការគ្រប់គ្រងទិន្នន័យរដ្ឋបាលទូទាំងប្រទេស។
- **សមាសភាពថ្នាក់ដឹកនាំភូមិ៖** ភូមិនីមួយៗមានថ្នាក់ដឹកនាំចំនួន **៣រូប** (មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ) ស្របតាមសេចក្តីណែនាំលេខ ០០៤ ស.ណ.ន។ តាមទិន្នន័យបច្ចុប្បន្ន ថ្នាក់ដឹកនាំភូមិនៅទូទាំងប្រទេសមានសរុបចំនួន **៤៣.៧៧០**រូប ក្នុងនោះស្ត្រីមានចំនួន **១២.៥២៨**រូប (ស្មើនឹង **២៩%** នៃចំនួនសរុប)។

បណ្ដាញថ្នាក់ដឹកនាំភូមិជាង **៤ម៉ឺនរូប**នេះ គឺជាកម្លាំងប្រតិបត្តិករជួរមុខដ៏សំខាន់ក្នុងការប្រមូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាសាស្ត្រ ការផ្សព្វផ្សាយគោលនយោបាយ ការប្រមូលព័ត៌មានតម្រូវការសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនិងជនងាយរងគ្រោះ ការថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ ព្រមទាំងការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងបញ្ហាបន្ទាន់នានាក្នុងសហគមន៍។

## III-សមិទ្ធផលការងារសំខាន់ៗ អាណត្តិទី៥(២០២២-២០២៥)៖

តាមរយៈការបូកសរុបលទ្ធផលការងារក្នុងរយៈពេលជាង៤ឆ្នាំមកនេះ បានបង្ហាញឱ្យឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ បានសម្រេចសមិទ្ធផលគួរឱ្យកត់សម្គាល់លើវិស័យជាច្រើន ដូចខាងក្រោម៖

### *១-ការពង្រឹងក្របខ័ណ្ឌគតិយុត្ត អំណាចបញ្ញត្តិ និងរបៀបរបបការងារ៖*

- **ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត៖** គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដោយមានលេខាធិការដ្ឋានគ.ជ.អ.ប ជាសេនាធិការ និងមានការចូលរួមយ៉ាងសកម្មពីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំនិងដាក់ឱ្យអនុវត្តនូវក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ មានចំនួន**៥៤** បន្ថែមលើលិខិតបទដ្ឋានប្រមាណជិត**៦០០** ដែលបានដាក់ចេញតាំងពីឆ្នាំ២០០២។ ក្នុងនោះមានលិខិតបទដ្ឋានគន្លឹះៗ រួមមាន៖ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣, អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់, អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន, អនុក្រឹត្យលេខ ២៤៩ អនក្រ.បក ស្តីពីការកំណត់អត្រាចែករំលែកពីសេវាសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋ, អនុក្រឹត្យលេខ ២៨០ អនក្រ.បក ស្តីពីការកំណត់លេខកូដសម្គាល់រដ្ឋបាល, ប្រកាសលេខ ១៨០ ស្តីពីសៀវភៅណែនាំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និងសារាចរអន្តរក្រសួងលេខ ០០៧ (២០២៥) ស្តីពីការគ្រប់គ្រងថវិកាសេវាសង្គម និងអនាម័យបរិស្ថាន។
- **ការប្រើប្រាស់អំណាចបញ្ញត្តិ និងកិច្ចការរដ្ឋបាល៖** ក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រើប្រាស់អំណាចបញ្ញត្តិស្របតាមច្បាប់ ដោយបានអនុម័តដាក់ចេញនូវដីកាសរុបចំនួន **១១.៥៨៦** ដីកា (ដូចជា ដីកាបទបញ្ជាផ្ទៃក្នុង ដីកាកំណត់តម្លៃសេវា ដីកាបង្កើតមត្តេយ្យសហគមន៍ និងការតែងតាំងជំនួយការហិរញ្ញវត្ថុ) ព្រមទាំងបានចេញសេចក្តីសម្រេច និងលិខិតរដ្ឋបាលនានាសរុបចំនួន **៤.៣១០.៩៤៧ច្បាប់** ដើម្បីចាត់ចែងការងាររដ្ឋបាល និងការផ្តល់សេវាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។
- **របៀបរបបប្រជុំក្រុមប្រឹក្សា៖** ដំណើរការប្រជុំតាមបែបប្រជាធិបតេយ្យនិងសមូហភាពត្រូវបានអនុវត្តជាប់ជាប្រចាំ ដោយបានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន **៧៩.២៩៦**លើក និងកិច្ចប្រជុំវិសាមញ្ញចំនួន**៦៣.៧៨២**លើក (ក្នុងនោះមានកិច្ចប្រជុំសម្ងាត់ចំនួន

**១.៨៨៩**លើក) ដើម្បីពិនិត្យ អនុម័ត និងដោះស្រាយបញ្ហាបន្ទាន់នានារបស់មូលដ្ឋាន បានទាន់ពេលវេលា។

*៦-ការគ្រប់គ្រងហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍ និងការវិនិយោគនៅមូលដ្ឋាន៖*

- **ការកើនឡើងនៃធនធានហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធមូលនិធិថ្មី៖** មូលនិធិឃុំ សង្កាត់ បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ពីប្រមាណជិត **៨**លានដុល្លារអាម៉េរិក (ឆ្នាំ២០០២) ដល់ប្រមាណ **៣៣៣**លានដុល្លារអាម៉េរិក (ក្នុងឆ្នាំ២០២៦ ដោយរួមបញ្ចូលទាំងការផ្ទេរបន្ថែម **១%** នៃចំណូលចរន្តថ្នាក់ជាតិ និងចំណូលពន្ធចែករំលែក **៦%**) ពិសេសមូលនិធិត្រូវបានកែសម្រួលជារចនាសម្ព័ន្ធ៣សមាសភាគច្បាស់លាស់ គឺ៖ (១) សមាសភាគរដ្ឋបាលទូទៅ, (២) សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន (ដែលបានកំណត់មុខសញ្ញាចំណាយលើ ១១វិស័យ), និង (៣) សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។
- **ការរៀបចំផែនការ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល៖** រដ្ឋបាលឃុំ សង្កាត់ បានរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជាប្រចាំ ដោយឈរលើការពិគ្រោះយោបល់ និងការចូលរួមពីប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការនៅថ្នាក់ក្រុង ស្រុក ខណ្ឌដើម្បីកៀរគរធនធានបន្ថែម។
- **ការអនុវត្តគម្រោងវិនិយោគប្រចាំឆ្នាំ៖** រដ្ឋបាលឃុំ សង្កាត់ បានរៀបចំនិងអនុវត្តគម្រោងវិនិយោគប្រចាំឆ្នាំ(២០២២-២០២៥)ដោយបានអនុវត្តបញ្ចប់គម្រោងឬសកម្មភាពជាច្រើន រួមមាន៖
  - ផ្នែកសេដ្ឋកិច្ចនិងហេដ្ឋារចនាសម្ព័ន្ធ៖ អនុវត្តសម្រេចបានចំនួន**៩.៨២៤គម្រោង ក្នុងនោះគម្រោង**សាងសង់និងកែលម្អផ្លូវបេតុងមានប្រវែងសរុប **៤.៥២០,៨២គ.ម** , ផ្លូវកៅស៊ូប្រវែង **៤០,២៣គ.ម**, ផ្លូវគ្រួសក្រហមប្រវែង **១១.៤៣៤,១៨** គ.ម និងស្ពានបេតុងខ្នាតតូចប្រវែង **២៩,១០គ.ម** ព្រមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូចដែលបានសម្រួលដល់ការធ្វើដំណើរ ការបង្កបង្កើនផល ការតភ្ជាប់ទីផ្សារ និងការជំរុញផលិតកម្មកសិកម្មនៅមូលដ្ឋាន។
  - ផ្នែកសង្គមកិច្ច៖ អនុវត្តសម្រេចបានចំនួន**៣៤.៦៣០**គម្រោង/សកម្មភាព ដោយផ្តោតលើមត្តេយ្យសិក្សាសហគមន៍ សុខភាពមាតានិងកុមារ អាហារូបត្ថម្ភ សុខភាពបន្តពូជ ទឹកស្អាត អនាម័យ និងកិច្ចការពារជនងាយរងគ្រោះ។

- ផ្នែកធនធានធម្មជាតិនិងបរិស្ថាន៖ អនុវត្តសម្រេចបានចំនួន**៧.៥៨៥គម្រោង**/ សកម្មភាព ដោយផ្តោតលើការគ្រប់គ្រងសំរាម សំណល់រឹងរាវ ការដាំដើមឈើ អភិរក្សព្រៃសហគមន៍ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់៖ អនុវត្តសម្រេចបានចំនួន១២.៥២២ គម្រោង/ សកម្មភាព ដោយផ្តោតលើការផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការល្បាត និងការទប់ស្កាត់បទល្មើសនៅមូលដ្ឋាន។

*៣-ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងកិច្ចគាំពារសង្គម៖* ដោយសាររដ្ឋបាលឃុំ សង្កាត់ជាថ្នាក់រដ្ឋបាលដែលនៅកៀកជិតប្រជាពលរដ្ឋបំផុតនិងមានឥទ្ធិពលដោយផ្ទាល់លើទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាលសាធារណៈ និងផ្អែកតាមតួនាទីដែលច្បាប់បានកំណត់ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចរៀបចំ និងចាត់ចែងសេវាសាធារណៈចាំបាច់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍រួម លើកកម្ពស់ផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។ នៅអាណត្តិទី៥នេះ ការផ្តល់សេវារដ្ឋបាលត្រូវបានបន្តពង្រឹងតាមយន្តការច្រកចេញចូលតែមួយ ដោយផ្តោតលើការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព គណនេយ្យភាព និងភាពរហ័ស ក្នុងនោះ រួមមាន៖

- **ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ៖** រដ្ឋបាលឃុំ សង្កាត់ បានផ្តល់សេវាអត្រានុកូលដ្ឋានចំនួនសរុប **៨.៥៨៧.១៥៦សេវា** (ជាមធ្យម **១.២៩៩ សេវា**/ ឃុំ-សង្កាត់/ឆ្នាំ )រួមមាន៖ ការចេញសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ មរណភាព និងសេចក្តីចម្លង និងបានសហការជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាល ផ្តល់សេវាអត្តសញ្ញាណកម្ម រួមមាន៖ផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ និងអត្តសញ្ញាណបណ្ណ សរុបចំនួន **៥.១៨២.០៤២សេវា**។
- **លិខិតបញ្ជាក់រដ្ឋបាលផ្សេងៗ៖** ចេញលិខិតបញ្ជាក់ភាពនៅលីវ លិខិតបញ្ជាក់លំនៅឋាន ការតបណ្តាញទឹកស្អាត អគ្គិសនី និងលិខិតបញ្ជាក់ផ្សេងៗ សរុបចំនួន **៩.០៥០.៨៧២ សេវា** (ជាមធ្យម **១.៣៧០** សេវា/ឃុំ-សង្កាត់/ឆ្នាំ )។
- **ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍៖** បានបន្តគ្រប់គ្រង និងដំណើរការមត្តេយ្យសិក្សាសហគមន៍ចំនួន **៣.៣៤៨កន្លែង** ស្ថិតក្នុងឃុំ សង្កាត់ចំនួន **១.១១៩** ( សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ ) ដោយមានគ្រូបង្រៀនកិច្ចសន្យាចំនួន **៣.៣៤៨នាក់** ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍកុមារតូច។

- **ការអនុវត្តកម្មវិធីជាតិគាំពារសង្គម៖** រដ្ឋបាលឃុំ សង្កាត់ និងមន្ត្រីភូមិ បានបំពេញតួនាទីស្នូលក្នុងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងក្រុមជនងាយរងហានិភ័យ ការផ្ទៀងផ្ទាត់ទិន្នន័យ ការចុះផ្សព្វផ្សាយដល់ខ្នងផ្ទះ និងការសម្របសម្រួលឱ្យប្រជាពលរដ្ឋទទួលបានបណ្ណសមធម៌ និងអត្ថប្រយោជន៍ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាលប្រកបដោយសមធម៌ និងបរិយាបន្ន។

*៤-ការសម្រុះសម្រួលដោះស្រាយវិវាទ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖*

- **ការសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការ៖** រដ្ឋបាលឃុំ សង្កាត់ បានដើរតួនាទីយ៉ាងមានប្រសិទ្ធភាពក្នុងការផ្សះផ្សា និងដោះស្រាយទំនាស់ក្នុងសហគមន៍។ ក្នុងអាណត្តិទី៥ រដ្ឋបាលឃុំ សង្កាត់ទទួលបានសំណើសុំសម្រុះសម្រួលសរុបចំនួន **២៣០.៤៨១ ករណី** (មធ្យម៣៥ ករណី/ឃុំ-សង្កាត់/ឆ្នាំ) ក្នុងនោះបានសម្រុះសម្រួលបញ្ចប់នៅថ្នាក់ឃុំ សង្កាត់បានចំនួន**២១៥.៧១៣ករណី**(ស្មើនឹង**៩៣%**)និងបញ្ជូនបន្តទៅស្ថាប័នមានសមត្ថកិច្ចចំនួន **១៤.៧៦៨ករណី** (ស្មើនឹង **៧%**) ដែលបានជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការនិងរក្សាបាននូវសាមគ្គីភាពក្នុងមូលដ្ឋាន។
- **ការអនុវត្តគោលនយោបាយ«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»៖** បានសហការជិតស្និទ្ធជាមួយប៉ុស្តិ៍នគរបាលរដ្ឋបាល និងកម្លាំងប្រជាការពារ ក្នុងការល្បាត ទប់ស្កាត់បទល្មើសគ្រឿងញៀន ក្មេងទំនើង និងអំពើហិង្សាក្នុងគ្រួសារ។ តាមរយៈការប្រឡងប្រណាំងប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ មានឃុំ សង្កាត់ចំនួន **១.២៤៣** ទទួលបានចំណាត់ថ្នាក់លេខ១, ចំនួន **៣៦៤** ទទួលបានលេខ២ និងចំនួន ៤១ ទទួលបានលេខ៣។
- **ការគាំទ្រការងារបោះឆ្នោត៖** បានសហការគាំទ្រ គ.ជ.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ដែលគិតត្រឹមឆ្នាំ២០២៥ មានប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន **១០.១៦២.២៣២នាក់**។ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៧ គ.ជ.ប បានចាប់ផ្តើមចែកលិខិតអញ្ជើញ(ប័ណ្ណព័ត៌មាន)អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២៥ ចាប់ថ្ងៃទី៧ ខែកញ្ញា ដល់ថ្ងៃទី៦ ខែតុលាឆ្នាំ២០២៦ និងចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតចាប់ពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦។

*៥-អភិបាលកិច្ច បរិវត្តកម្មឌីជីថល និងការកសាងសមត្ថភាព៖*

- **ការងារគណនេយ្យភាពសង្គម (ISAF)៖** ត្រូវបានពង្រីកវិសាលភាពគ្របដណ្ដប់ទូទាំងប្រទេស រួមមាន៖ រដ្ឋបាលឃុំ សង្កាត់ចំនួន **១.៥៥០** (ស្មើនឹង **៩៤%**), សាលាបឋមសិក្សាចំនួន **៦.៩២២** (ស្មើនឹង **៩៤%**) និងមណ្ឌលសុខភាពចំនួន **១.២៥៦** (ស្មើនឹង **៩៦%**) នៅក្នុងក្រុង ស្រុក ខណ្ឌចំនួន **១៩០** នៃរាជធានី-ខេត្តទាំង ២៥ ដែលបានលើកកម្ពស់តម្លាភាព និងការចូលរួមត្រួតពិនិត្យពីប្រជាពលរដ្ឋ។
- **ការធ្វើបរិវត្តកម្មឌីជីថល៖** បានដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាសំខាន់ៗ រួមមានប្រព័ន្ធ FMIS Portal សម្រាប់ស្នើនិងបញ្ជូនឯកសារចំណាយ, ប្រព័ន្ធតាមដានថវិការដ្ឋបាលឃុំ សង្កាត់ និងកម្មវិធីឌីជីថលគណនេយ្យភាពសង្គម ដែលជួយកាត់បន្ថយការប្រើក្រដាស បង្កើនល្បឿន និងពង្រឹងភាពត្រឹមត្រូវនៃទិន្នន័យ។
- ការកសាងសមត្ថភាព និងភាពជាដៃគូ៖ សមាជិកក្រុមប្រឹក្សា ស្មៀន និងបុគ្គលិក បានចូលរួមវគ្គបណ្ដុះបណ្ដាលនានាសរុបចំនួន **១៤៤.៣៣៧ វគ្គ/លើក** ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ក្នុងការលើកកម្ពស់សមត្ថភាព និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន។

## IV-ការវាយតម្លៃរួម និងបញ្ហាប្រឈម៖

***១-ការវាយតម្លៃរួមលើផលជះជាវិជ្ជមាន៖*** ផ្អែកលើលទ្ធផលនៃការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ (២០២២-២០២៥) យើងអាចវាយតម្លៃបានថា រដ្ឋបាលឃុំ សង្កាត់បានបង្កើតនូវផលជះជាវិជ្ជមាន និងការផ្លាស់ប្ដូរជាយុទ្ធសាស្ត្រយ៉ាងច្រើនលើការគ្រប់គ្រង និងការអភិវឌ្ឍមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់បានបន្តវិវត្តយ៉ាងពិតប្រាកដ ពីអង្គភាពដែលផ្ដោតជាចម្បងលើការងាររដ្ឋបាលលិខិតស្នាម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទៅជារដ្ឋបាលមូលដ្ឋានពហុវិស័យ ដែលបំពេញតួនាទីស្នូលលើការផ្ដល់សេវាសាធារណៈ សេវាសង្គម កិច្ចគាំពារសង្គម បរិស្ថាន គណនេយ្យភាព សន្តិសុខ និងការធ្វើបរិវត្តកម្មឌីជីថល។ ផលជះជាវិជ្ជមានសំខាន់ៗដែលសម្រេចបាន រួមមាន៖

- **ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចនៅមូលដ្ឋាន៖** ដំណើរការដឹកនាំតាមបែបសមូហភាព ភាពជាតំណាងរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពត្រូវបានពង្រឹងជាលំដាប់។

- **លើកកម្ពស់ការតភ្ជាប់ និងសេដ្ឋកិច្ចមូលដ្ឋាន៖** ការស្តារ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន និងធារាសាស្ត្រ បានសម្រួលដល់ការដឹកជញ្ជូន និងបង្កើតឱកាសមុខរបរជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។
- ការនាំសេវារដ្ឋឱ្យកាន់តែកៀកប្រជាពលរដ្ឋ៖ ការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ បានកាត់បន្ថយពេលវេលា និងការចំណាយរបស់ប្រជាពលរដ្ឋ។
- **បង្កើនការវិនិយោគលើមូលធនមនុស្ស និងសុខុមាលភាព៖** ការបង្កើតសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន បានផ្តល់ធនធានជាក់លាក់សម្រាប់គាំទ្រមត្តេយ្យសហគមន៍ សុខភាពមាតានិងកុមារ និងអាហារូបត្ថម្ភ។
- **ពង្រឹងការគាំពារក្រុមងាយរងគ្រោះ៖** ការកំណត់អត្តសញ្ញាណ និងការផ្សព្វផ្សាយកម្មវិធីជាតិជំនួយសង្គម បានធានាឱ្យគ្រួសារក្រីក្រ និងជនងាយរងគ្រោះទទួលបានផលប្រយោជន៍ដោយមិនបោះបង់នរណាម្នាក់ចោល។
- **រក្សាសន្តិសុខ និងសាមគ្គីភាពសហគមន៍៖** ការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងប្រសិទ្ធភាពនៃការសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការ បានកាត់បន្ថយទំនាស់ និងរក្សាភាពសុខសាន្តក្នុងមូលដ្ឋាន។
- **លើកកម្ពស់តម្លាភាព និងទំនើបកម្មរដ្ឋបាល៖** ការអនុវត្តការងារគណនេយ្យភាពសង្គម និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល បានជួយឱ្យការគ្រប់គ្រងទិន្នន័យ និងថវិកាមានភាពច្បាស់លាស់ និងអាចត្រួតពិនិត្យបាន។

ទន្ទឹមនឹងវឌ្ឍនភាពទាំងនេះ ការបូកសរុបនិងវាយតម្លៃក៏បានបង្ហាញនូវចំណុចខ្វះខាតផ្នែកសូចនាករវាស់វែងផងដែរ ដោយការកត់ត្រានិងរាយការណ៍បច្ចុប្បន្ននៅផ្តោតខ្លាំងលើ «ទិន្នផល/បរិមាណដែលបានធ្វើ» ដូចជា ចំនួនគម្រោង ប្រវែងផ្លូវ ឬចំនួនសេវា ខណៈទិន្នន័យអំពី «ផលសម្រេចនិងការផ្លាស់ប្តូរជីវភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ» នៅមិនទាន់ត្រូវបានចងក្រង និងឆ្លុះបញ្ចាំងឱ្យបានពេញលេញនៅឡើយទេ។

***២-បញ្ហាប្រឈមគន្លឹះសំខាន់ៗ៖*** ទោះបីសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់យ៉ាងណាក្តី ការអនុវត្តការងាររបស់ក្រុមប្រឹក្សា និងរដ្ឋបាលឃុំ សង្កាត់ ក្នុងអាណត្តិទី៥ នៅតែជួបប្រទះនូវបញ្ហាប្រឈម និងឧបសគ្គមួយចំនួន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពិនិត្យ ដោះស្រាយជាយុទ្ធសាស្ត្រ រួមមានដូចខាងក្រោម៖

- **បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងនីតិវិធីថវិកា៖** ការផ្ទេរធនធានពីថវិកាជាតិក្នុងឆ្នាំនីមួយៗនៅមានភាពយឺតយ៉ាវ ដោយរដ្ឋបាលឃុំ សង្កាត់មួយចំនួនត្រូវរង់ចាំរហូតដល់ការបើកផ្តល់ថវិកានៅត្រីមាសទី៣ ទើបមានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការគម្រោង និង

ទូទាត់ជូនអ្នកទទួលការ ដែលកត្តានេះបណ្តាលឱ្យការអនុវត្តគម្រោងត្រូវប្រមូលផ្តុំគ្នានៅចុងឆ្នាំ និងបង្កផលប៉ះពាល់ដល់ការគ្រប់គ្រងកិច្ចសន្យា។

- **ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ខុសគោលដៅនិងខុសនីតិវិធី៖** រដ្ឋបាលឃុំ សង្កាត់មួយចំនួនមិនបានដំណើការរៀបចំនិងការអនុវត្តគម្រោងមូលនិធិឱ្យបានត្រឹមត្រូវតាមនិតិវិធីហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្មសាធារណៈដោយបានអនុម័តកែតម្រូវគម្រោងថវិកាឃុំ សង្កាត់ លើផ្នែកអភិវឌ្ឍន៍មកបំពេញបន្ថែមក្នុងគម្រោងដែលបានដេញថ្លៃរួច ដោយមិនបានឆ្លងកាត់និតិវិធីលទ្ធកម្ម និងបានយកថវិកាដែលបានកែតម្រូវមកបូកបន្ថែមលទ្ធផលគម្រោងនៅពេលចុះកិច្ចសន្យាអនុវត្តគម្រោងជាមួយអ្នកទទួលការ ភាគច្រើនលើសលប់បន្ថែមទៅលើគម្រោងណា ដែលមានតម្លៃឯកតាខ្ពស់ ដែលនាំឱ្យគម្រោងនោះមានតម្លៃខ្ពស់ហួសហេតុលើសតម្លៃទីផ្សារ ។ ការអនុវត្តរបៀបនេះគឺបង្ហាញនូវសញ្ញាណនៃការរៀបចំគិតទុកជាមុន ឬជាការគប់គិតគ្នាជាប្រព័ន្ធ ក្នុងការ រៀបចំឯកសារដេញថ្លៃ ការកំណត់លក្ខខណ្ឌបង្រួមការប្រកួតប្រជែង ការបែងចែក ឬសម្របសម្រួលអ្នកទទួលបានគម្រោង ការវាយតម្លៃដេញថ្លៃខុសនីតិវិធី ការក្លែងបន្លំឯកសារ ការបង្កើតទិន្នន័យមិនពិត ឬការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ដែលប្រើប្រាស់ថវិកាខុសគោលដៅ ខុសផែនការ ខុសលក្ខខណ្ឌបច្ចេកទេស និងខុសកិច្ចសន្យា ខ្វះតម្លាភាព សុច្ចរិតភាព និងអយុត្តិធម៌សម្រាប់អ្នកទទួលការផ្សេងៗទៀត។ (ករណីនេះ ប្រហែលអង្គសន្និបាតបានដឹងច្បាស់ទាំងអស់គ្នារួចហើយ ហើយមិនមែនកើតមានឡើងតែនៅខេត្តកំពង់ឆ្នាំងមួយនោះទេ តាមការចុះត្រួតពិនិត្យស្រាវជ្រាវរបស់អគ្គនាយកដ្ឋានរដ្ឋបាល គឺកើតឡើងមានច្រើននៅតាមបណ្តាខេត្តផ្សេងផងដែរ ដូច្នេះ សូមឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត បន្តយកចិត្តទុកខ្ពស់ដាក់លើកិច្ចការនេះ។

- **បន្ទុកការងារ និងកង្វះខាតធនធានមនុស្ស៖** មុខងារ ភារកិច្ច និងប្រព័ន្ធបច្ចេកវិទ្យាត្រូវបានផ្ទេរ និងដាក់ឱ្យអនុវត្តកាន់តែច្រើន ខណៈរដ្ឋបាលឃុំ សង្កាត់នីមួយៗមានស្មៀនតែ១រូប ដែលជាហេតុបង្កឱ្យមានសម្ពាធការងារខ្ពស់ និងប្រឈមនឹងការកកស្ទះ។ ទន្ទឹមនេះ បុគ្គលិកកិច្ចសន្យា (ជំនួយការរដ្ឋបាល ហិរញ្ញវត្ថុ សេវាសង្គម និងគ្រូមត្តេយ្យ) នៅប្រឈមនឹងបញ្ហាកម្រិតប្រាក់ឧបត្ថម្ភទាប កង្វះឱកាសអភិវឌ្ឍអាជីព និងអស្ថិរភាពការងារ។

- **ភាពមិនទាន់ស៊ីសង្វាក់គ្នានៃការធ្វើសមាហរណកម្មគម្រោង៖** ការរៀបចំសិក្ខាសាលាសមាហរណកម្មផែនការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ មិនទាន់ទទួលបានការ

សន្យា និងការគាំទ្រធនធានជាក់លាក់ពីមន្ទីរ-អង្គភាពជំនាញ និងដៃគូនានា ដែលធ្វើឱ្យគម្រោងអាទិភាពជាច្រើនរបស់ឃុំ សង្កាត់មិនអាចអនុវត្តបានតាមការគ្រោងទុក។

- **គុណភាព និងភាពត្រឹមត្រូវនៃការផ្តល់សេវា៖** ឯកសារអត្រានុកូលដ្ឋាននៅមានកំហុសឆ្គងច្រើនពាក់ព័ន្ធនឹងអក្ខរាវិរុទ្ធ ឈ្មោះ និងថ្ងៃខែឆ្នាំកំណើត ហើយនីតិវិធីកែតម្រូវនៅមានភាពស្មុគស្មាញ និងប្រើពេលយូរ។ ការផ្តល់សន្លឹកអត្តសញ្ញាណបណ្ណជូនប្រជាពលរដ្ឋក្រោយពេលថតរួច នៅមានភាពយឺតយ៉ាវក្នុងករណីមួយចំនួន ព្រមទាំងទម្រង់លិខិតបញ្ជាក់រដ្ឋបាលមិនទាន់មានទម្រង់ឯកភាពដូចគ្នានៅគ្រប់មូលដ្ឋាន។
- **គម្លាតសមត្ថភាពក្នុងការធ្វើបរិវត្តកម្មឌីជីថល៖** ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា បណ្តាញអ៊ីនធឺណិត និងបរិក្ខារបច្ចេកវិទ្យានៅតាមឃុំ សង្កាត់ដាច់ស្រយាលនៅមានកម្រិត ខណៈចំណេះដឹង និងជំនាញឌីជីថលរបស់មន្ត្រីមូលដ្ឋានមួយចំនួននៅមិនទាន់ទាន់សម័យកាល ដែលទាមទារការបណ្តុះបណ្តាលជាប្រព័ន្ធបន្ថែមទៀត។
- **វិសមភាពនៃការអភិវឌ្ឍនៅមូលដ្ឋាន៖** ស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងធនធានរវាងឃុំ សង្កាត់ ទីប្រជុំជន ជនបទ ព្រំដែន និងតំបន់កោះ នៅមានគម្លាតខុសគ្នាខ្លាំង ដែលធ្វើឱ្យកម្រិតនៃការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋមិនទាន់មានភាពស្មើគ្នានៅឡើយ។

## V-ទិសដៅជាយុទ្ធសាស្ត្រ សម្រាប់អាណត្តិទី៦៖

ផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងអាណត្តិទី៥ ជាពិសេសការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការកើនឡើងធនធាន ការពង្រីកសេវាសាធារណៈនិងសេវាសង្គម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការគាំពារសង្គម ការរក្សាសន្តិសុខសហគមន៍ និងការចាប់ផ្តើមធ្វើបរិវត្តកម្មឌីជីថល ព្រមទាំងផ្អែកលើបញ្ហាប្រឈមដែលនៅសេសសល់ ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ត្រូវបន្តពង្រឹងសមិទ្ធផលទាំងនេះ និងកែប្រែរបៀបបំពេញការងារពីការផ្តោតលើនីតិវិធី និងបរិមាណសកម្មភាព ទៅរកការគ្រប់គ្រងផ្អែកលើលទ្ធផល គុណភាពសេវា ការពេញចិត្តរបស់ប្រជាពលរដ្ឋ សមធម៌ បរិយាបន្ន និងចីរភាព។ ទិសដៅនេះត្រូវអនុវត្តឱ្យស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដោយផ្សារភ្ជាប់អាទិភាព «មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា» ទៅនឹងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ ក្នុងនោះរួមមាន៖

## ១-ចក្ខុវិស័យ និងគោលការណ៍គ្រឹះ៖

- **ចក្ខុវិស័យ៖** កសាងក្រុមប្រឹក្សា និងរដ្ឋបាលឃុំ សង្កាត់ឱ្យក្លាយជារដ្ឋបាលមូលដ្ឋាន តាមបែបប្រជាធិបតេយ្យ ដែលមានសមត្ថភាព ភាពម្ចាស់ការ តម្លាភាព គណនេយ្យភាព បរិយាបន្ន ភាពឆ្លើយតប និងភាពធន់ ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសមស្រប ដើម្បីផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងដឹកនាំការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយចីរភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពង្រឹងតួនាទីជាស្ថាប័នតំណាងប្រជាពលរដ្ឋ ជាស្ថាប័នធ្វើសេចក្តីសម្រេច ជាអ្នកដឹកនាំការអភិវឌ្ឍមូលដ្ឋាន ជាអ្នកសម្របសម្រួលសេវា និងជាស្ពានតភ្ជាប់រវាងប្រជាពលរដ្ឋជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់។
- **គោលការណ៍គ្រឹះចំនួន ៧ ចំណុច៖**
  - ➢ ប្រជាពលរដ្ឋជាមជ្ឈមណ្ឌល ដោយការរៀបចំផែនការ ថវិកា ការផ្តល់សេវា និងការវាយតម្លៃ ត្រូវចាប់ផ្តើមពីតម្រូវការអាទិភាព និងការពេញចិត្តរបស់ប្រជាពលរដ្ឋ។
  - ➢ ការផ្ទេរមុខងារ និងភារកិច្ចត្រូវភ្ជាប់ជាមួយធនធានហិរញ្ញវត្ថុ បុគ្គលិក សិទ្ធិសម្រេច សមត្ថភាពអនុវត្ត និងខ្សែគណនេយ្យភាពច្បាស់លាស់។
  - ➢ ការរៀបចំផែនការ និងថវិកាត្រូវផ្អែកលើទិន្នន័យត្រឹមត្រូវ មានការចូលរួម និងភ្ជាប់គ្នារវាងអាទិភាព គម្រោង ធនធាន និងលទ្ធផលដែលចង់សម្រេច។
  - ➢ ការអភិវឌ្ឍត្រូវមានបរិយាបន្ន សមធម៌ និងគោរពគោលការណ៍ «មិនបោះបង់នរណាម្នាក់ចោល» ដោយយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី កុមារ យុវជន គ្រួសារក្រីក្រ ជនងាយរងគ្រោះ និងតំបន់មានគម្លាតអភិវឌ្ឍន៍។
  - ➢ ការគ្រប់គ្រងថវិកា លទ្ធកម្ម និងគម្រោងត្រូវគោរពច្បាប់និងនីតិវិធី ប្រកាន់ខ្ជាប់សុចរិតភាព តម្លាភាព ការប្រកួតប្រជែងដោយស្មើភាព គុណភាព តម្លៃសមស្របនឹងថវិកា និងចីរភាព។
  - ➢ បរិវត្តកម្មឌីជីថលត្រូវជួយសម្រួលនីតិវិធី បង្កើនល្បឿននិងភាពត្រឹមត្រូវនៃការងារ ពង្រឹងការតភ្ជាប់ទិន្នន័យ និងកាត់បន្ថយបន្ទុករដ្ឋបាលរបស់មន្ត្រីមូលដ្ឋាន។
  - ➢ ការតាមដាន វាយតម្លៃ និងគណនេយ្យភាពសង្គមត្រូវផ្អែកលើផលសម្រេច ផលប៉ះពាល់ និងភស្តុតាងជាក់ស្តែង ព្រមទាំងបង្ហាញលទ្ធផលឆ្លើយតបត្រឡប់ទៅប្រជា-ពលរដ្ឋ។

## ៦-វិធានការអនុវត្តគន្លឹះសំខាន់ៗ៖

**ទី១-លើកកម្ពស់គុណភាពសេវាសាធារណៈ និងសេវារដ្ឋបាលដោយយកប្រជាពលរដ្ឋជាមជ្ឈមណ្ឌល៖**

- បន្តពង្រឹងសមិទ្ធផលនៃយន្តការច្រកចេញចូលតែមួយ ដោយកំណត់ស្តង់ដាសេវា ពេលវេលា តម្លៃ និងអ្នកទទួលខុសត្រូវឱ្យច្បាស់លាស់ ហើយវាស់វែងលទ្ធផលតាមភាពរហ័ស ភាពត្រឹមត្រូវ តម្លាភាព និងការពេញចិត្តរបស់ប្រជាពលរដ្ឋ។
- កែលម្អភាពត្រឹមត្រូវនៃទិន្នន័យអត្រានុកូលដ្ឋាន ធ្វើឱ្យនីតិវិធីកែតម្រូវកាន់តែសាមញ្ញ និងពន្លឿនការផ្តល់សន្លឹកអត្តសញ្ញាណបណ្ណជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។
- កែលម្អទីតាំងច្រកចេញចូលតែមួយនៅសាលាឃុំ សង្កាត់ បំពាក់ឧបករណ៍ព័ត៌មានវិទ្យាចាំបាច់ និងបង្កើតយន្តការទទួលនិងដោះស្រាយមតិយោបល់ ឬបណ្តឹងរបស់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

**ទី២-ពង្រឹងការផ្ទេរមុខងារ និងការគ្រប់គ្រងធនធានមនុស្ស៖**

- រាល់ការផ្ទេរមុខងារ និងភារកិច្ចថ្មីមកឲឃុំ សង្កាត់ ត្រូវកំណត់ឱ្យច្បាស់អំពីធនធានហិរញ្ញវត្ថុ បុគ្គលិកគាំទ្រ សិទ្ធិសម្រេច នីតិវិធីអនុវត្ត ការបណ្តុះបណ្តាល និងខ្សែគណនេយ្យភាព ដើម្បីកុំឱ្យបង្កបន្ទុកលើសសមត្ថភាពរដ្ឋបាលមូលដ្ឋាន។
- ពិនិត្យនិងរៀបចំការបែងចែកការងារ ការប្រគល់សិទ្ធិ និងការជំនួសវេនរវាងស្មៀន និងជំនួយការរដ្ឋបាលឱ្យបានច្បាស់ ដើម្បីធានានិរន្តរភាពសេវា និងកាត់បន្ថយការកកស្ទះការងារ។
- ពិនិត្យលទ្ធភាពលើកកម្ពស់ប្រាក់ឧបត្ថម្ភ ស្ថិរភាពការងារ និងឱកាសអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកកិច្ចសន្យា ព្រមទាំងបន្តលើកកម្ពស់តួនាទីស្ត្រី និងយុវជនក្នុងភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍមូលដ្ឋាន។

**ទី៣-កែលម្អការគ្រប់គ្រងថវិកា លទ្ធកម្ម និងការផ្ទេរធនធាន៖**

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ដើម្បីកំណត់និងអនុវត្តកាលវិភាគផ្ទេរថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ឱ្យបានទាន់ពេលវេលានៅដើមឆ្នាំ និងតាមដានការអនុវត្តជាប្រចាំ ដើម្បីជៀសវាងការប្រមូលផ្តុំគម្រោងនិងការទូទាត់នៅត្រីមាសចុងក្រោយ។
- ពង្រឹងការរៀបចំនិងប្រើប្រាស់ថវិកាលើសមាសភាគទាំងបីឱ្យចំអាទិភាព ជាពិសេសសេវាសង្គម និងអនាម័យបរិស្ថាន ព្រមទាំងរឹតបន្តឹងការអនុវត្តនីតិវិធីហិរញ្ញវត្ថុ និងលទ្ធកម្ម

តាមរយៈការប្រកួតប្រជែងដោយស្មើភាព ការបង្ហាញព័ត៌មាន ការត្រួតពិនិត្យបច្ចេកទេស និងការទទួលខុសត្រូវចំពោះការប្រើប្រាស់ថវិកាខុសគោលដៅ ឬខុសកិច្ចសន្យា។

**ទី៤-ពង្រឹងប្រសិទ្ធភាពផែនការ ការវិនិយោគ និងការសមាហរណកម្មគម្រោង៖**

- រៀបចំផែនការ និងជ្រើសរើសគម្រោងដោយផ្អែកលើទិន្នន័យ តម្រូវការអាទិភាព និងផលប្រយោជន៍សេដ្ឋកិច្ច-សង្គម ដោយផ្លាស់ប្តូរពីការផ្តោតលើបរិមាណសំណង់ទៅរកគុណភាពបច្ចេកទេស តម្លៃសមស្របនឹងថវិកា ភាពធន់នឹងអាកាសធាតុ និងការថែទាំបានយូរអង្វែង។
- ពង្រឹងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យទទួលបានការប្តេជ្ញាចិត្តគាំទ្រជាក់លាក់ពីមន្ទីរ អង្គភាពជំនាញ និងដៃគូអភិវឌ្ឍន៍ ដោយបញ្ជាក់ស្ថាប័នគាំទ្រ គម្រោង ឆ្នាំអនុវត្ត និងទំហំថវិកា ព្រមទាំងមានប្រព័ន្ធតាមដានលទ្ធផលនៃការសន្យាទាំងនោះ។

**ទី៥-ជំរុញបរិវត្តកម្មឌីជីថល និងទំនើបកម្មប្រព័ន្ធការងារ៖**

- បន្តសហការពង្រីកការប្រើប្រាស់ប្រព័ន្ធឌីជីថលដែលមានស្រាប់ ដូចជា FMIS Portal ប្រព័ន្ធតាមដានថវិកា និងប្រព័ន្ធគណនេយ្យភាពសង្គម ព្រមទាំងបំពាក់បរិក្ខារបច្ចេកវិទ្យា បណ្តាញអ៊ីនធឺណិត និងការគាំទ្របច្ចេកទេសឱ្យបានសមស្របដល់គ្រប់សាលាឃុំ សង្កាត់។
- រៀបចំការបណ្តុះបណ្តាលជំនាញឌីជីថលតាមកម្រិតសមត្ថភាព និងតាមតួនាទីការងារ ធ្វើឱ្យប្រព័ន្ធទិន្នន័យអាចភ្ជាប់និងប្រើប្រាស់រួមគ្នាបាន ព្រមទាំងពង្រឹងសុវត្ថិភាពទិន្នន័យ ដើម្បីឈានទៅពង្រីកសេវាសាធារណៈតាមប្រព័ន្ធអនឡាញ។

**ទី៦-ពង្រឹងការគាំពារសង្គម សមភាពយេនឌ័រ បរិស្ថាន និងភាពធន់របស់សហគមន៍៖**

- បន្តពង្រឹងតួនាទីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងការវិនិយោគលើមត្តេយ្យសិក្សាសហគមន៍ សុខភាពមាតានិងកុមារ និងអាហារូបត្ថម្ភ ព្រមទាំងលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងយុវជនក្នុងការធ្វើសេចក្តីសម្រេចនៅមូលដ្ឋាន។
- លើកកម្ពស់គុណភាព និងតម្លាភាពនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដើម្បីធានាឱ្យការផ្តល់ជំនួយសង្គម និងបណ្ណសមធម៌ចំមុខសញ្ញា យុត្តិធម៌ និងមិនមានការរើសអើង។

- បង្កើនសកម្មភាពគ្រប់គ្រងសំណល់រឹងនិងរាវ ការប្រមូលសំរាម ទឹកស្អាតនិងអនាម័យ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការត្រៀមឆ្លើយតបគ្រោះមហន្តរាយ និងការរក្សាសន្តិសុខ សុវត្ថិភាព និងសាមគ្គីភាពសហគមន៍។

**ទី៧-កែលម្អប្រព័ន្ធតាមដាន វាយតម្លៃ និងគណនេយ្យភាពផ្អែកលើផលសម្រេច៖**

- បង្កើតសូចនាករ ទិន្នន័យគោល និងគោលដៅប្រចាំឆ្នាំសម្រាប់វាស់វែងមិនត្រឹមតែចំនួនសកម្មភាព ឬលទ្ធផលផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគុណភាពសេវា ការពេញចិត្តរបស់ប្រជាពលរដ្ឋ ផលសម្រេច និងការប្រែប្រួលជីវភាពជាក់ស្តែង ដោយបែងចែកទិន្នន័យតាមភេទ ក្រុមងាយរងគ្រោះ និងតំបន់នៅពេលចាំបាច់។
- ពង្រឹងការងារគណនេយ្យភាពសង្គម (ISAF) ឱ្យក្លាយជាវដ្តពេញលេញ ចាប់ពីការផ្សព្វផ្សាយព័ត៌មាន ការវាយតម្លៃរបស់ប្រជាពលរដ្ឋ ការរៀបចំផែនការកែលម្អ ការអនុវត្ត និងតាមដាន រហូតដល់ការបង្ហាញលទ្ធផលឆ្លើយតប និងការកែលម្អសេវាត្រឡប់ទៅប្រជាពលរដ្ឋវិញប្រកបដោយតម្លាភាព។

## VI-សេចក្តីសន្និដ្ឋានរួម៖

ការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ក្នុងរយៈពេលជាង៤ឆ្នាំកន្លងមក (២០២២-២០២៥) បានប្រព្រឹត្តទៅក្នុងដំណាក់កាលប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញយ៉ាងមុតស្រួចនូវកំណែទម្រង់អភិបាលកិច្ច កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពខ្ពស់ ស្របតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២(២០២១-២០៣០)និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ផ្អែកលើការបូកសរុប វិភាគ និងវាយតម្លៃសមិទ្ធផលការងារសម្រេចបានក្នុងអាណត្តិទី៥នេះ អាចសន្និដ្ឋានបានថា៖

**១-ភាពរឹងមាំនៃលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន៖** ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាប់ជាទៀងទាត់អស់រយៈពេល ៥អាណត្តិ និងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលមានសមាជិកសរុបចំនួន **១១.៦២២រូប** នៅទូទាំង **១.៦៥២ ឃុំ សង្កាត់** បានបញ្ជាក់យ៉ាងច្បាស់អំពីភាពស្របច្បាប់ ភាពជាតំណាងពិតប្រាកដរបស់ប្រជាពលរដ្ឋ និងការចាក់គ្រឹះយ៉ាងរឹងមាំនៃប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។

**២-ការផ្លាស់ប្តូរជាយុទ្ធសាស្ត្រនៃរដ្ឋបាលមូលដ្ឋាន៖** រដ្ឋបាលឃុំ សង្កាត់ បានបោះជំហានវិវត្តយ៉ាងច្បាស់លាស់ ពីអង្គភាពដែលផ្តោតជាចម្បងលើការងាររដ្ឋបាល លិខិតស្នាម និងការសាង

សង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទៅជារដ្ឋបាលមូលដ្ឋានដែលមានតួនាទីពហុវិស័យកាន់តែទូលំទូលាយ ទាំងលើការផ្តល់សេវាសាធារណៈ សេវាសង្គម កិច្ចគាំពារសង្គម ការអប់រំកុមារតូច កិច្ចការពារស្ត្រី និងកុមារ អនាម័យបរិស្ថាន ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ គណនេយ្យភាពសង្គម និងការធ្វើបរិវត្តកម្មឌីជីថល។

**៣-ការបម្លែងគោលនយោបាយជាតិទៅជាសកម្មភាពជាក់ស្តែង៖** ក្រុមប្រឹក្សា និងរដ្ឋបាលឃុំ សង្កាត់ បានដើរតួនាទីយ៉ាងសកម្មជាស្ពានតភ្ជាប់រវាងរាជរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ក្នុងការបម្លែងគោលនយោបាយ ច្បាប់ និងកម្មវិធីជាតិ ទៅជាផែនការ ថវិកា គម្រោងវិនិយោគ និងសេវាសាធារណៈជាក់ស្តែង ដែលឆ្លើយតបចំតម្រូវការចាំបាច់ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ទន្ទឹមនឹងសមិទ្ធផលដ៏ត្រចះត្រចង់ទាំងនេះ របាយការណ៍ក៏បានបង្ហាញយ៉ាងច្បាស់នូវបញ្ហាប្រឈម គម្លាតសមត្ថភាព ធនធាន និងកត្តាភូមិសាស្ត្រ ដែលធ្វើឱ្យកម្រិតនៃការអនុវត្តការងារនៅមិនទាន់មានភាពស្មើគ្នានៅគ្រប់មូលដ្ឋាននៅឡើយ។ យ៉ាងណាក៏ដោយ បទពិសោធ និងមេរៀនដែលទទួលបានក្នុងអាណត្តិទី៥ គឺជាមូលដ្ឋានគ្រឹះ និងជាធាតុចូលយុទ្ធសាស្ត្រដ៏មានតម្លៃបំផុតសម្រាប់ត្រួសត្រាយផ្លូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ អាចបន្តពង្រឹងប្រសិទ្ធភាពការងារ ភាពម្ចាស់ការ តម្លាភាព និងគណនេយ្យភាព សំដៅឈានទៅសម្រេចបាននូវការគ្រប់គ្រងដែលផ្តោតលើលទ្ធផល គុណភាពសេវា សមធម៌ បរិយាបន្ន និងចីរភាព។

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងក្នុងនាមអង្គសន្និបាតទាំងមូល ខ្ញុំបាទសូមប្តេជ្ញាខិតខំយកចិត្តទុកដាក់ប្រមូលរាល់មតិយោបល់ ជាធាតុចូល និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ព្រមទាំងគណៈអធិបតី ដើម្បីកែសម្រួលនិងរៀបចំឯកសារយុទ្ធសាស្ត្រ គោលការណ៍ណែនាំ និងវិធានការគាំទ្រនានាឱ្យកាន់តែមុតស្រួច សម្រាប់ដាក់ចេញឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ អនុវត្តការងារបម្រើជាតិ និងប្រជាពលរដ្ឋទទួលបានជោគជ័យកាន់តែធំធេងបន្ថែមទៀត។

ខ្ញុំបាទសូមបញ្ចប់នូវសេចក្តីរាយការណ៍ស្តីពីសាវតារ សមាសភាព សមិទ្ធផលការងារសំខាន់ៗ បញ្ហាប្រឈម និងទិសដៅ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងសម្រាប់អនុវត្តអាណត្តិទី៦ ដោយសង្ខេបតែត្រឹមនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំសព្ទសាធុការពរជ័យបវរសួស្តី សិរីមង្គល

វិបុលសុខ មហាប្រសើរ ជូនចំពោះ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល សូមសមប្រកបដោយពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពថ្លែងអំណរគុណ!**